# RHB Pay Anyone™ - **សម្រាប់អ្នកផ្ញើ**

1.1 និយមន័យនិងការបកស្រាយ : លុះត្រាតែមានការបកស្រាយនិងការប្រើប្រាស់ផ្ទុយពីនេះ ពាក្យនិងកន្សោមពាក្យខាងក្រោម មានអត្ថន័យដូចតទៅ៖

"លេខកូដសម្ងាត់" មានន័យថាជាលេខអត្តសញ្ញាណ ដែលផ្តល់អោយអ្នកទទួលដោយអ្នកផ្ញើរ ដើម្បីសម្រួលដល់ការទទួលប្រាក់ តាម RHB Pay Anyone™។

"ធនាគារ" មានន័យថាធនាគារ RHB Indochina Bank Limited (លេខចុះបញ្ជីក្រុមហ៊ុន៖ 00001812) ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងបានទទួលអាជ្ញាប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការធនាគារពីធនាគារជាតិនៃកម្ពុជាហើយមានអសយដ្ឋានចុះបញ្ជីនៅផ្ទះលេខ 263 ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ដោយរួមបញ្ចូលទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធ អ្នកតំណាងឬអ្នកចាត់តាំងណាមួយ។

"សេវា RHB Pay Anyone™" សំដៅលើសេវាធនាគារមួយ ដែលអនុញ្ញាត្តិអោយអតិថិជនរបស់ធនាគារ RHB (អ្នកផ្ញើ) ធ្វើប្រតិបត្តិការផ្ញើរប្រាក់ ឬ ទូទាត់ប្រាក់ទៅកាន់នរណាម្នាក់ (អ្នកទទួល)។ អ្នកទទួល អាចទទួលប្រាក់បានតាមរយៈ RHB Pay Anyone™ ជម្រើសបណ្តាញឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow។

"ការទូទាត់តាមរយៈ RHB Pay Anyone™" សំដៅលើប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីរបស់អ្នកផ្ញើ ដែលមាននៅធនាគារRHB ទៅកាន់អ្នកទទួលណាម្នាក់ដោយប្រើប្រាស់សេវា RHB Pay Anyone™ ។

"RHB Pay Anyone ™ ជម្រើសបណ្តាញ"សំដៅលើ ការទទួលយកប្រាក់ពីការផ្ទេរប្រាក់តាមរយៈ RHB Pay Anyone™ទៅក្នុងគណនីរបស់អ្នកទទួលដែលមាន នៅធនាគារណាមួយដែលជាសមាជិករបស់ប្រព័ន្ធទូទាត់ប្រាក់រហ័ស(FAST)តាមរយៈគេហទំព័រ https://rhbnow.rhbgroup.com/kh/payanyone/ ។

"ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow" សំដៅលើការទទួលយកប្រាក់ពីការផ្ទេរប្រាក់តាមរយៈ RHB Pay Anyone ™ ទៅក្នុងគណនីរបស់អ្នកទទួលដែលមាននៅធនាគារណាមួយដែលជាសមាជិករបស់ប្រព័ន្ធទូទាត់រហ័ស) FAST) តាមរយៈការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow ។

"គោលការណ៍ឯកជន" សំដៅលើគោលនយោបាយនិងគោលការណ៍របស់ធនាគារទាក់ទងនឹងការទទួលប្រាក់ ការប្រើប្រាស់និងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលនិងស្ថាប័នដែលទាក់ទងនឹងធនាគារ ហើយអាចត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់និងបង្ហាញនៅលើគេហទំព័ររបស់ធនាគារ ឬនៅក្នុងបទដ្ឋានណាមួយដែលធនាគារយល់ថាសមស្របនិងចាំបាច់។

"អ្នក" សំដៅលើអ្នកផ្ញើ។ អ្នកផ្ញើគឺជាបុគ្គលដែលធ្វើប្រតិបត្តិការ RHB Pay Anyone ™ ហើយស្នើសុំឱ្យសេវា RHB Pay Anyone ™ ធ្វើការទូទាត់ ឬផ្ញើរប្រាក់អោយអ្នកទទួល។

1.2 លោកអ្នកត្រូវទទួលនិងយល់ព្រមចំពោះលក្ខខណ្ឌនិងខចែងទាំងនេះមុនពេលប្រើប្រាស់សេវាកម្ម RHB Pay Anyone™ តាមរយៈការចុះឈ្មោះដោយជោគជ័យក្នុងនាមជាអ្នកប្រើប្រាស់កម្មវិធីធនាគារអ៊ីនធឺណែត និង/ឬ កម្មវិធីធនាគារចល័ត របស់ធនាគារ RHB ហើយចូលទៅកាន់សេវាកម្មនោះ លោកអ្នកយល់ព្រមនិងទទួលស្គាល់ថាលក្ខខណ្ឌនិងខចែងទាំងនេះមានឥទ្ធិពលលើលោកអ្នក និងត្រូវបានចាត់ទុកថាជាកិច្ចព្រមព្រៀង រវាងលោកអ្នក (អតិថិជន) និងធនាគារយើងខ្ញុំ (ធនាគា អ អេច ប៊ី ឥណ្ឌូនេណា "ធនាគារ") សម្រាប់ការចូល/ឬការប្រើប្រាស់។

1.3 សេវា RHB Pay Anyone ™ អនុញ្ញាតឱ្យអ្នកផ្ទេរប្រាក់ទៅអ្នកទទួលណាម្នាក់តាមរយៈលេខទូរស័ព្ទ(កម្ពុជា) អ៊ីម៉ែល ឬ គណនីហ្វេសប៊ុក ដែលអ្នកបានចុះបញ្ជី។ អ្នកទទួលប្រាក់អាចទទួលយកប្រាក់ តាមរយៈ RHB Pay Anyone ™ ជម្រើសបណ្តាញ ឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow ។ ដើម្បីទទួលសិទ្ធិក្នុងការប្រើប្រាស់សេវា RHB Pay Anyone™ អ្នកត្រូវៈ -

១. ជាអតិថិជនរបស់ធនាគារ និងជាអ្នកដែលកំពុងប្រើប្រាស់កម្មវិធីធនាគារតាមអ៊ីនធឺណែត និង/ឬ កម្មវិធីធនាគារចល័ត RHBNow
២. បានដំឡើងកម្មវិធី RHBNow ធនាគារចល័ត លើស្មាតហ្វូនរបស់អ្នករួចរាល់ហើយ។
៣. មានគណនីសន្សំ ឬគណនីចរន្តបុគ្គល ដែលមានសុពលភាពជាមួយធនាគារ។
៤. អនុលោមតាមលក្ខខណ្ឌ និង ខចែង ទាំងនេះ។

1.4 ប្រសិនបើអ្នកចង់ធ្វើប្រតិបត្តិការ RHB Pay Anyone™ អ្នកត្រូវដាក់សំណើធ្វើប្រតិបត្តិការ ដើម្បីចាប់ផ្តើមប្រតិបត្តិការ RHB Pay Anyone™ តាមរយៈកម្មវិធីធនាគារចល័ត RHBNow ។ ដោយផ្អែកលើពត៌មានលំអិតដែលផ្តល់ដោយអ្នក ធនាគារនឹងផ្ញើរការជូនដំណឹងដល់អ្នកទទួល តាមរយៈ សារខ្លី (សារអេឡិចត្រូនិក) អ៊ីម៉ែលឬគណនីហ្វេសប៊ុក អំពីការទូទាត់ តាមរយៈ RHB Pay Anyone™ ដែលអ្នកបានផ្ញើអ្នកទទួលដើម្បីធ្វើការទទួលប្រាក់ ។ ដើម្បីដាក់សំណើប្រតិបត្តិការ អ្នកត្រូវៈ -

១ ផ្តល់ព័ត៌មានដែលធនាគារ ស្នើសុំ (រាប់បញ្ចូលទាំងព័ត៌មានលម្អិតសំរាប់ទំនាក់ទំនងអ្នកទទួល) និង
២ ទទួលបានលេខកូដសម្ងាត់ ១ ខ្ទង់ពីធនាគារតាមរយៈសារអេឡិចត្រូនិកហើយលេខកូដសម្ងាត់នេះនឹងត្រូវបានប្រើប្រាស់ដោយអ្នកទទួលដើម្បីទទួលទឹកប្រាក់ដែលបានទូទាត់តាមរយៈប្រតិបត្តិការ RHB Pay Anyone™ ។
លេខកូដសម្ងាត់នេះនឹងផុតកំណត់ក្នុងរយៈពេលបី (3)ថ្ងៃ រាប់ចាប់ពីថ្ងៃដែលសំណើប្រតិបត្តិការត្រូវបានទទួលយកដោយធនាគារ ("រយៈពេលមានសុពលភាព") ។ ព័ត៌មាននេះត្រូវបានបញ្ជាក់នៅលើទំព័រព័ត៌មានលម្អិតនៃការផ្ទេរប្រាក់ដែលផ្តល់ឱ្យអ្នកនៅពេលដែលអ្នកដាក់សំណើ។

1.5 សូមប្រាកដថាព័ត៌មានដែលអ្នកបានផ្តល់អោយគឺត្រឹមត្រូវ។ នៅពេលដែលដាក់សំណើប្រតិបត្តិការ RHB Pay Anyone™ រួចរាល់ហើយអ្នកមិនអាចលុបចោលឬធ្វើការផ្លាស់ប្តូរណាមួយទៅលើសំណើនោះទេ។

1.6 ធនាគារមានសិទ្ធិសំរេច ក្នុងការពន្យារពេល បញ្ឈប់ បដិសេធមិនដំណើរការ ឬលុបចោល សំណើប្រតិបត្តិការទូទាត់តាមរយៈ RHB Pay Anyone ™ ដោយមិនចាំបាច់តម្រូវឱ្យផ្តល់ហេតុផលណាមួយចំពោះ ការពន្យារពេល បញ្ឈប់ បដិសេធមិនដំណើរការ ឬលុបចោលនេះឡើយ។

1.7 ប្រតិបត្តិការ RHB Pay Anyone ™ នឹងត្រូវធ្វើឡើងនៅក្នុងថ្ងៃតែមួយពីគណនីរបស់អ្នក។ ទន្ទឹមនឹងការរង់ចាំអ្នកទទួលធ្វើប្រតិបត្តិការទទួលប្រាក់, ចំនួនទឹកប្រាក់នៃការទូទាត់ ("ចំនួនទឹកប្រាក់ដកទុក")នឹងត្រូវបានកាត់ចេញពីគណនីរបស់អ្នក ដើម្បីត្រៀមទុកសម្រាប់ប្រតិបត្តិការនេះ។ ប្រសិនបើអ្នកទទួល មិនបានធ្វើប្រតិបត្តិការទទួលប្រាក់នោះទេ ចំនួនទឹកប្រាក់ដែលបានដកទុកនេះនឹងត្រូវបានបង្វិលត្រលប់ទៅគណនីរបស់អ្នកវិញបន្ទាប់ពីរយៈពេលបី (3)ថ្ងៃគិត ចាប់ពីថ្ងៃដែលប្រតិបត្តិការត្រូវបានទទួលយកដោយធនាគារ ("រយៈមានពេលសុពលភាព") ។

1.8 RHB Pay Anyone ™ ជម្រើសបណ្តាញ ដោយអ្នកទទួល: -

១. អ្នកទទួលត្រូវមានលេខកូដសម្ងាត់ដើម្បីធ្វើការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ ។

២. លេខកូដសម្ងាត់ត្រូវបានផ្តល់ជូនអ្នកតាមរយៈសារអេឡិចត្រូនិកដោយធនាគារនៅពេលដែលប្រតិបត្តិការ RHB Pay Anyone™ របស់លោកអ្នកត្រូវបានបញ្ជាក់។

៣. អ្នកត្រូវផ្តល់កូដលេខសម្ងាត់ ទៅអោយអ្នកទទួលតែម្នាក់គត់តាមរយៈការទំនាក់ទំនងតាមទូរស័ព្ទដោយផ្ទាល់។ អ្នកមិនត្រូវ:

ក. បង្ហាញលេខកូដសម្ងាត់ទៅបុគ្គលផ្សេងទៀតក្រៅពីអ្នកទទួលឡើយ។

ខ. អនុញ្ញាតឱ្យបុគ្គលផ្សេងទៀតក្រៅពីអ្នកទទួល មើល ឬ ស្តាប់ឮលោកអ្នកផ្តល់លេខកូដសម្ងាត់។

គ. កត់ត្រាលេខកូដសម្ងាត់ លើកន្លែងដែលងាយបាត់បង់ លួច ឬបន្លំ។

៤. ប្រសិនបើលេខកូដសម្ងាត់ត្រូវបានផ្តល់អោយទៅបុគ្គលណាម្នាក់ក្រៅពីអ្នកទទួល បុគ្គលនោះនឹងអាចធ្វើការទទួលប្រាក់ពីការទូទាត់តាមរយៈ RHB Pay Anyone ™ ជំនួសអ្នកទទួលបាន។

៥.បន្ទាប់ពីផ្តល់លេខកូដសម្ងាត់ទៅអ្នកទទួលអ្នកទទួលត្រូវចូលទៅកាន់គេហទំព័រ https://rhbnow.rhbgroup.com/kh/payanyone/ ហើយបំពេញព័ត៌មានដូចខាងក្រោម:

ក. ជ្រើសវិធីសាស្រ្តក្នុងការទទួលប្រាក់ តាមរយៈ ១)ទូរស័ព្ទចល័ត ២) អ៊ីម៉ែល ឬ ៣) គណនីហ្វេសប៊ុក ផ្អែកលើការណែនាំដែលទទួលបាន

ខ. បំពេញ ១) លេខទូរស័ព្ទចល័ត ១) អស័យដ្ឋានអ៊ីម៉ែល ឬ ៣) ឈ្មោះគណនីហ្វេសប៊ុក

គ. បំពេញលេខកូដសម្ងាត់

ឃ. បំពេញពត៌មានលំអិតពីគណនីធនាគារដែលអ្នកចង់អោយការទូទាត់តាមរយៈ RHB Pay Anyone ™ ធ្វើការដាក់ប្រាក់ចូល។

៦.ប្រសិនបើព័ត៌មានណាមួយខាងលើបំពេញមិនបានត្រឹមត្រូវ នោះការទទួលប្រាក់ពីការទូទាត់តាម រយៈ RHB Pay Anyone ™ អាចនឹងមិនទទួលជោគជ័យ។ រាល់ព័ត៌មានលំអិតដែលបានបញ្ចូលដោយអ្នកទទួលនៅលើគេហទំព័រ https://rhbnow.rhbgroup.com/kh/payanyone/ ត្រូវតែជាក់លាក់ និង ត្រឹមត្រូវ។ ក្នុងអំឡុងពេលដំណើរការ ការទូទាត់តាមរយៈ RHB Pay Anyone ™ ធនាគារមិនមានកាតព្វកិច្ចពិនិត្យ ពីភាពត្រឹមត្រូវនិង/ឬបញ្ជាក់ពីសុពលភាពនៃលេខគណនី ដែលផ្តល់ដោយអ្នកទទួលឡើយ។

៧. ប្រសិនបើអ្នកទទួលបរាជ័យក្នុងការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone ™ ក្នុងរយៈពេលបី (៣) ថ្ងៃ ចាប់ពីថ្ងៃនៃសំណើប្រតិបត្តិការត្រូវបានទទួលដាក់ដំណើរការដោយធនាគារ នោះចំនួនទឹកប្រាក់ដែលបានដកទុក នឹងត្រូវបានបង្វិលចូលទៅក្នុងគណនីរបស់លោកអ្នកវិញ ហើយអ្នកទទួលមិនអាចធ្វើការទទួលប្រាក់ពីការទូទាត់តាម RHB Pay Anyone ™ នេះបានទៀតឡើយ។

៨. ធនាគារនឹងជូនដំណឹងដល់អ្នកតាមរយៈសារអេឡិចត្រូនិកលើគ្រប់ប្រតិបត្តិការការទូទាត់តាម RHB Pay Anyone ™ ដែលទទួលជោគជ័យ។ ធនាគារនឹងជូនដំណឹងផងដែរចំពោះរាល់ប្រត្តិបត្តិការការទូទាត់តាម RHB Pay Anyone ™ ដែលអ្នកទទួលមិនបានធ្វើការទទួលប្រាក់ ក្នុងរយៈពេលបី (៣) ថ្ងៃ។

1.9 ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow ដោយអ្នកទទួល: -

១. អ្នកទទួលត្រូវមានលេខកូដសម្ងាត់ដើម្បីធ្វើការទទួលប្រាក់ ពី ការទូទាត់តាម RHB Pay Anyone ™។

២. លេខកូដសម្ងាត់ត្រូវបានផ្តល់ជូនលោកអ្នកតាមរយៈសារអេឡិចត្រូនិចដោយធនាគារនៅពេលដែល ប្រតិបត្តិការ RHB Pay Anyone ™ របស់អ្នកត្រូវបានបញ្ជាក់។

៣. លោកអ្នកត្រូវផ្តល់លេខកូតសម្ងាត់ទៅអោយអ្នកទទួលតែម្នាក់គត់តាមរយៈការទំនាក់ទំនងតាមទូរស័ព្ទដោយផ្ទាល់។ លោកអ្នកមិនត្រូវ:

ក. បង្ហាញលេខកូដសម្ងាត់ទៅបុគ្គលផ្សេងទៀតក្រៅពីអ្នកទទួលឡើយ។

ខ. អនុញ្ញាតឱ្យបុគ្គល ផ្សេងទៀតក្រៅពីអ្នកទទួល មើល ឬ ស្តាប់ឮលោកអ្នកផ្តល់លេខសម្ងាត់។

គ. ការកត់ត្រាលេខកូដសម្ងាត់ លើកន្លែងដែលងាយបាត់បង់ លួច ឬបន្លំ។

៤. ប្រសិនបើលេខកូដសម្ងាត់ត្រូវបានផ្តល់អោយទៅបុគ្គលណាម្នាក់ក្រៅពីអ្នកទទួល បុគ្គលនោះនឹងអាចធ្វើការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone ™ ជំនួសអ្នកទទួលបាន។

៥. បន្ទាប់ពីផ្តល់លេខកូដសម្ងាត់ទៅអ្នកទទួល អ្នកទទួលត្រូវ ទាញយកកម្មវិធីធនាគារចល័ត RHBNow ពី App Store ឬ Play Store ហើយជ្រើសរើស "RHB Pay Anyone™" ហើយបំពេញព័ត៌មានដូចខាងក្រោម:

ក. ជ្រើសវិធីសាស្រ្តក្នុងការទទួលប្រាក់តាមរយៈ ១)ទូស័ព្ទចល័ត ២) អ៊ីម៉ែលឬ ៣) គណនីហ្វេសប៊ុកដោយផ្អែកលើការណែនាំដែលទទួលបាន

ខ. បំពេញ ១) លេខទូរស័ព្ទចល័ត ២) អ៊ីម៉ែល ឬ ៣) ឈ្មោះគណនីហ្វេសប៊ុក

គ. បំពេញលេខកូដសម្ងាត់

ឃ. បំពេញពត៌មានលំអិតពីគណនីធនាគារដែលពួកគាត់ចង់អោយការទូទាត់តាមសេវា RHB Pay Anyone ™ ធ្វើការដាក់ប្រាក់ចូល។

៦. ប្រសិនបើព័ត៌មានណាមួយខាងលើបំពេញមិនបានត្រឹមត្រូវនោះ ការទទួលប្រាក់ពីការទូទាត់តាម RHB Pay Anyone ™ អាចនឹងមិនទទួលបានជោគជ័យ។ រាល់ព័ត៌មានលំអិតដែលបានបញ្ចូលដោយអ្នកទទួលនៅក្នុងការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow ត្រូវតែជាក់លាក់ និង ត្រឹមត្រូវ។ ក្នុងអំឡុងពេល ដំណើរការ ការទូទាត់តាមសេវា RHB Pay Anyone ™ ធនាគារមិនមានកាតព្វកិច្ចផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ និង/ឬបញ្ជាក់ពីសុពលភាពនៃលេខគណនី ដែលផ្តល់ដោយអ្នកទទួលឡើយ។

៧. ប្រសិនបើអ្នកទទួលបរាជ័យក្នុងការទទួលប្រាក់ពី ការទូទាត់តាមសេវា RHB Pay Anyone ™ ក្នុងរយៈពេលបី (៣) ថ្ងៃ ចាប់ពីថ្ងៃ សំណើប្រតិបត្តិការត្រូវបានទទួលដោយធនាគារ ចំនួនទឹកប្រាក់ដែលបានដកទុក នឹងត្រូវបានបង្វិលចូលទៅក្នុងគណនីរបស់លោកអ្នកជាវិញ ហើយអ្នកទទួលមិនអាចទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone ™ នេះបានទៀតឡើយ។

1.10 អ្នកយល់ព្រមផ្តល់ ដំណឹងដល់អ្នកទទួលថាអ្នកបានផ្តល់ព័ត៌មាន អំពីលេខទូរស័ព្ទ/ អាស័យដ្ឋានអ៊ីម៉ែល / ឈ្មោះគណនីហ្វេសប៊ុករបស់ពួកគាត់ដល់ធនាគារ ក្នុងគោលបំណងដើម្បីអោយធនាគារអាចផ្តល់ដំណឹងជូនពួកគាត់អំពី ការទូទាត់តាម RHB Pay Anyone ™។

1.11 វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការធានាថាព័ត៌មានលំអិតដែលផ្តល់អោយ គឺត្រឹមត្រូវ បើមិនដូច្នោះទេ ការទូទាត់តាមសេវា RHB Pay Anyone ™ របស់អ្នកអាចនឹងមិនទទួលបានជោគជ័យ ឬកអាចត្រូវនឹងបានទូទាត់ទៅកាន់បុគ្គលណាម្នាក់ផ្សេងទៀត។ ធនាគារមិនមានកាតព្វកិច្ចផ្ទៀងផ្ទាត់ថាព័ត៌មានលំអិតដែលផ្តល់ដោយអ្នកគឺត្រឹមត្រូវនោះឡើយ។

1.12 ប្រសិនបើអ្នកទទួលមានបំណងតវ៉ាលើការទូទាត់តាម RHB Pay Anyone™ ដែលមិនទទួលជោគជ័យ និង/ឬចំនួនទឹកប្រាក់ដែលទទួលបានពី ការទូទាត់តាម RHB Pay Anyone ™ នោះអ្នកទទួល ត្រូវទាក់ទងទៅអ្នកដោយផ្ទាល់។

1.13 ធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ណាមួយ របស់អ្នក ឬ អ្នកទទួល បើការបាត់បង់នោះកើតឡើងដោយៈ

ក. ការបង្ហាញលេខកូដសម្ងាត់ទៅបុគ្គលផ្សេងទៀតក្រៅពីអ្នកទទួល។ លេខកូដសម្ងាត់របស់អ្នកគឺជាការសម្ងាត់របស់អ្នក ហើយមិនគួរត្រូវបានចែករំលែកជាមួយបុគ្គលផ្សេងទៀតឡើយក្រៅពីអ្នកទទួល។ អ្នកត្រូវប្រុងប្រយ័ត្នជានិច្ចចំពោះការទូទាត់តាមសេវា RHB Pay Anyone ™ទៅកាន់បុគ្គលណាម្នាក់ដែលអ្នកមិនស្គាល់។ ក្នុងករណីណាក៏ដោយ ធនាគារ RHB នឹងមិនទទួលខុសត្រូវឡើយ ប្រសិនបើអ្នកផ្តល់លេខកូដសម្ងាត់ទៅបុគ្គលផ្សេងទៀតក្រៅពីអ្នកទទួល។

ខ. អ្នកបរាជ័យក្នុងការផ្តល់លេខកូដសម្ងាត់ទៅអ្នកទទួល។

គ. អ្នកបរាជ័យក្នុងការយល់អំពីរបៀបប្រតិបត្តិការ/ការប្រើប្រាស់សេវានេះ ឬបរាជ័យដោយសារការអនុវត្តន៍ដោយការខ្វះការប្រុងប្រយ័ត្នក្នុងការធានាសុវត្ថិភាពលេខកូដសម្ងាត់និងព័ត៌មានផ្សេងទៀត។

1.14 ធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ឬការខូចខាតណាមួយ ដែលបង្កដោយបុគ្គលណាមួយដែលជាលទ្ធផលពីៈ

ក. ការបរាជ័យ ឬការពន្យាពេលណាមួយ ដោយអ្នក ក្នុងការផ្តល់លេខកូដសម្ងាត់ត្រឹមត្រូវសម្រាប់ការទូទាត់តាមរយៈ RHB Pay Anyone™ ឱ្យអ្នកទទួល។

ខ. ប្រសិនបើបុគ្គលណាម្នាក់ក្រៅពីអ្នកទទួលបានដឹងពីលេខសម្ងាត់ លើកតែកើតឡើយដោយសារការលួចបន្លំឬធ្វេសប្រហែសរបស់បុគ្គលិកឬភ្នាក់ងាររបស់ធនាគារ។

គ. ប្រសិនបើអ្នកទទួលបានវាយបញ្ចូលលេខកូដសម្ងាត់មិនត្រឹមត្រូវ ក្នុងកំឡុងពេលធ្វើប្រតិបត្តិការទទួលប្រាក់ការទូទាត់តាមសេវា RHB Pay Anyone™ ។

ឃ. ប្រសិនបើធនាគារពន្យារពេល បញ្ឈប់ បដិសេធមិនដំណើរការ ឬលុបចោល សំណើ ប្រតិបត្តិការទូទាត់តាមសេវា RHB Pay Anyone™ ដោយមូលហេតុណាមួយ និង

ង. ក្នុងករណីណាក៏ដោយ ធនាគារនឹងទទួលខុសត្រូវចំពោះការមិនទទួលបានឬមានការយឺតយ៉ាវក្នុងផ្ញើសារជូនដំណឹងទៅកាន់លោកអ្នកឬអ្នកទទួល។

1.15 ក្នុងមួយថ្ងៃ លោកអ្នកអាចផ្ទេរប្រាក់បានត្រឹមចំនួនទឹកប្រាក់ប្រតិបត្តិការអតិបរិមាសរុបចំនួន USD1,000.00 តែប៉ុណ្ណោះ ( សំណើប្រតិបត្តិការតែមួយដងឬច្រើនដង) ។ ដែនកំណត់អតិបរិមាប្រចាំថ្ងៃនៃសេវា RHB Pay Anyone ™ នេះបានកំណត់ឡើងដោយយោងទៅតាមដែនកំណត់អតិបរិមារបស់ប្រព័ន្ធទូទាត់រហ័ស (FAST) របស់ធនាគារជាតិនៃកម្ពុជា។ នេះគឺជាដែនកំណត់អតិបរមាដែលបានអនុញ្ញាតហើយដែនកំណត់នេះនឹងត្រូវបានកំណត់ឡើងវិញជាប្រចាំថ្ងៃនៅពាក់កណ្តាលអធ្រាត្រ (ម៉ោងកម្ពុជា) ។ ធនាគារ រក្សាសិទ្ធិសំរេចការផ្លាស់ប្តូរ ឬ ដាក់បន្ថែម លើដែនកំណត់ទំហំទឹកប្រាក់អតិបរិមារនៃការទូទាត់ឬផ្ទេរ ក្នុងមួយប្រតិបត្តិការឬច្រើនប្រតិបត្តិការ ដោយការជូនដំណឹងជាមុន។

1.16 លោកអ្នកទទួលស្គាល់និងយល់ព្រមថា តាមរយៈសេវា RHB Pay Anyone ™,កម្មវិធីធនាគារចល័ត RHB Now នឹងចូលទៅប្រើប្រាស់ព័ត៌មាននៅក្នុងគណនី Facebook របស់អ្នក និង / ឬព័ត៌មានទំនាក់ទំនង (ឧទាហរណ៍ ឈ្មោះអ្នកទទួល លេខទូរស័ព្ទដៃ អាស័យដ្ឋានអ៊ីម៉ែល) ដែលបានផ្ទុកនៅលើទូរស័ព្ទដៃរបស់អ្នក ហើយអ្នកអនុញ្ញាតអោយធនាគារប្រើប្រាស់ព័ត៌មាននេះសម្រាប់ការផ្តល់សេវា RHB Pay Anyone ™ និងយល់ព្រមឱ្យធនាគារទាក់ទងទៅអ្នកទទួលដែលអ្នកបានកំណត់ ដោយប្រើព័ត៌មានទាំងនេះ (រួមទាំងការចូលទៅកាន់ ទំព័រ Facebook ឯកជនរបស់អ្នកទទួលតាមរយៈគណនី Facebook របស់អ្នក) ជំនួសអោយលោកអ្នក។

1.17 ធនាគារសូមរក្សាសិទ្ធិក្នុងការគិតថ្លៃសេវាកម្ម 1.00 ដុល្លារអាមេរិក និងរក្សាសិទ្ធិធ្វើការកែប្រែថ្លៃសេវាកម្មប្រើប្រាស់ និង/ឬការស្នើសុំប្រើប្រាស់សេវា RHB Pay Anyone ™ ឡើងវិញ ដោយ ការជូនដំណឹងដល់លោកអ្នកជាមុនជាលាយលក្ខណ៍អក្សរ។ ការផ្លាស់ប្តូរ ឬការកែប្រែថ្លៃសេវាកម្មនេះនឹងមានសុពលភាពចាប់ពីថ្ងៃដែលបានកំណត់នៅក្នុងសេចក្តីជូនដំណឹង។ ប្រសិនបើលោកអ្នកនៅតែបន្តប្រើប្រាស់កម្មវិធីធនាគារចល័ត RHBNow ឬដាក់សំណើប្រតិបត្តិការ RHB Pay Anyone ™ ណាមួយបន្ទាប់ពីការជូនដំណឹងនេះ អ្នកត្រូវបានចាត់ទុកថាបានយល់ព្រមនិងទទួលយកការផ្លាស់ប្តូរ ឬការកែប្រែថ្លៃសេវាកម្មនេះ។

1.18 ការបញ្ជូនសារអេឡិចត្រូនិកទាក់ទងនឹងសេវា RHB Pay Anyone™

១. ធនាគារនិង/ឬអ្នកផ្តល់សេវារបស់ខ្លួនមិនទទួលខុសត្រូវ ហើយក៏មិនមានការគ្រប់គ្រងអ្វីទាំងអស់ទៅលើការកកស្ទះសារអេឡិចត្រូនិក កំហុសបច្ចេកទេសបណ្តាញនិង/ឬការរំខានផ្សេងៗទៅលើសារ ដែលជាលទ្ធផលបណ្តាលមកពីអ្នកផ្តល់សេវាបណ្តាញទូរស័ព្ទចល័តរបស់អ្នក ក្នុងអំឡុងពេលដំណើរការផ្ញើសារជូនលោកអ្នក ដែលធ្វើអោយលោកអ្នកមិនអាចទទួលបាន ឬ ពន្យាពេលក្នុងការទទួលបានសារអេឡិចត្រូនិក បន្ទាប់ពីការស្នើសុំធ្វើប្រតិបត្តិការ RHB Pay Anyone™ របស់លោកអ្នក ។

២. អ្នកត្រូវទទួលខុសត្រូវនិងធានាថាព័ត៌មានលំអិតសម្រាប់ការទំនាក់ទំនងរបស់អ្នកព្រមទាំង អ្នកទទួល (សម្រាប់ការទូទាត់តាមសេវាRHB Pay Anyone™) ត្រូវបានធ្វើបច្ចុប្បន្នភាព ត្រឹមត្រូវ ជាក់លាក់និងពេញលេញ។ ប្រសិនបើអ្នកបរាជ័យក្នុងការបំពេញលក្ខខ័ណ្ឌនេះធនាគារនិង/ឬអ្នកផ្តល់សេវារបស់ខ្លួនមិនទទួលខុសត្រូវចំពោះការមិនបានទទួលសារអេឡិចត្រូនិក បន្ទាប់ពីការស្នើសុំប្រតិបត្តិការ RHB Pay Anyone ™នេះឡើយ។

៣.ធនាគារនិង/ឬអ្នកផ្តល់សេវារបស់ខ្លួននឹងមិនត្រូវទទួលខុសត្រូវ ប្រសិនបើអ្នកផ្តល់សេវាបណ្តាញទូរស័ព្ទរបស់អ្នក និង/ឬ របស់អ្នកទទួល មិនអាចគាំទ្រដល់ការទទួលសារអេឡិចត្រូនិកពីធនាគារដោយសារតែហេតុផលណាមួយ។

ដូចនេះមុនពេលប្រើប្រាស់សេវា RHB Pay Anyone™ អ្នកត្រូវទទួលខុសត្រូវនិងធានាថាអ្នកផ្តល់សេវាបណ្តាញទូរស័ព្ទចល័តរបស់អ្នកនិង/ឬអ្នកទទួល (ការទូទាត់តាម RHB Pay Anyone™) មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគាំទ្រដល់ទទួលសារអេឡិចត្រូនិកពីធនាគារនិង/ឬអ្នកផ្តល់សេវារបស់ខ្លួន។

1.23 ការទូទាត់សំណង

អ្នកយល់ព្រមនិងទទួលស្គាល់ថាធនាគារមិនមានការធានាឬ អះអាងណាមួយ ទៅលើ កម្មវិធីធនាគារអ៊ីនធឺណែត កម្មវិធីធនាគារចល័ត RHBNOw និង/ឬ សេវា RHB Pay Anyone™ ដែលផ្តល់ដោយធនាគារឡើយ។ ធនាគារមិនធានានិងទទួលខុសត្រូវចំពោះការបាត់បង់ផ្សេងៗរបស់អ្នកឬបុគ្គលផ្សេងទៀត ដែលកើតឡើងដោយការមិនគោរពតាមកិច្ចសន្យាឬសំណងទាក់ទងនឹងលក្ខខណ្ឌនេះ។

RHB Pay Anyone™ - សម្រាប់អ្នកទទួល

ល័ក្ខខ័ណ្ឌនិងខចែងនៃការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ ដោយអ្នកទទួលតាមរយៈ RHB Pay Anyone ™ ជម្រើសបណ្តាញ ឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow

1.20 និយមន័យនិងការបកស្រាយៈ លុះត្រាតែមានការបកស្រាយនិងការប្រើប្រាស់ផ្ទុយពីនេះ ពាក្យនិងកន្សោមពាក្យខាងក្រោម មានអត្ថន័យដូចតទៅ៖

"លេខកូដសម្ងាត់" មានន័យថាជាលេខអត្តសញ្ញាណ ដែលផ្តល់អោយអ្នកទទួលដោយអ្នកផ្ញើរ ដើម្បីសម្រួលដល់ការទទួលប្រាក់តាមសេវា RHB Pay Anyone™។

"ធនាគារ" មានន័យថាធនាគារ RHB Indochina Bank Limited (លេខចុះបញ្ជីក្រុមហ៊ុន៖ 00001812) ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងបានទទួលអាជ្ញាប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការធនាគារពីធនាគារជាតិនៃកម្ពុជាហើយមានអស័យដ្ឋានចុះបញ្ជីនៅផ្ទះលេខ 263 ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជានិង រួមបញ្ចូលទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធ អ្នកតំណាងឬអ្នកចាត់តាំងណាមួយ។

"អ្នកផ្ញើ" សំដៅលើបុគ្គលដែលធ្វើប្រតិបត្តិការ RHB Pay Anyone ™ និងស្នើសុំឱ្យមានការទូទាត់តាមសេវា RHB Pay Anyone ™ ឱ្យទៅអ្នកទទួល"

"អ្នកផ្ញើ" មានន័យថាបុគ្គលដែលធ្វើប្រតិបត្តិការ RHB Pay Anyone™ និងស្នើឱ្យមានការទូទាត់តាមRHB Pay Anyone™ ឱ្យទៅអ្នកទទួល"

“សេវា RHB Pay Anyone™” សំដៅលើសេវាធនាគារមួយ ដែលអនុញ្ញាត្តិអោយអតិថិជនរបស់ធនាគារ RHB (អ្នកផ្ញើ) ធ្វើប្រតិបត្តិការផ្ញើរប្រាក់ ឬ ទូទាត់ប្រាក់ទៅកាន់អ្នកតាមរយៈ RHB Pay Anyone ™ ជម្រើសបណ្តាញឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow។

"ការទូទាត់តាមរយៈ RHB Pay Anyone™" សំដៅលើប្រតិបត្តិការផ្ទេរប្រាក់ ពីគណនីរបស់អ្នកផ្ញើ ដែលមានមាននៅធនាគារRHBទៅអោយអ្នកដោយប្រើប្រាស់សេវា RHB Pay Anyone ™ ។

"RHB Pay Anyone ™ ជម្រើសបណ្តាញ" សំដៅលើការផ្ទេរប្រាក់នៃការទូទាត់តាមរយៈ RHB Pay Anyone ™ ទៅក្នុង គណនីរបស់អ្នកនៅ ធនាគារណាមួយដែលជាសមាជិករបស់ប្រព័ន្ធទូទាត់ប្រាក់រហ័ស (FAST) តាមរយៈគេហទំព័រ https://rhbnow.rhbgroup.com/kh/payanyone/ ។

"ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow"សំដៅលើ ការផ្ទេរប្រាក់នៃការទូទាត់តាមរយៈ RHB Pay Anyone ™ ទៅក្នុងគណនីរបស់អ្នក ដែលមាននៅធនាគារណាមួយ ដែល ជាសមាជិកក្នុងប្រព័ន្ធទូទាត់ឆាប់រហ័ស (FAST) តាមរយៈ កម្មវិធីធនាគារចល័ត RHBNow ។

"គោលការណ៍ឯកជន" សំដៅលើគោលនយោបាយនិងគោលការណ៍របស់ធនាគារទាក់ទងនឹងកាទទួលប្រាក់ ការប្រើប្រាស់និងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលនិងស្ថាប័នដែលទាក់ទងនឹងធនាគារហើយអាចត្រូវបានធ្វើវិសោធនជាបន្តបន្ទាប់ និង បង្ហាញនៅលើគេហទំព័ររបស់ធនាគារ ឬនៅក្នុងបទដ្ឋានណាមួយដែលធនាគារយល់ថាសមស្របនិងចាំបាច់។

"អ្នក" សំដៅលើអ្នកទទួលប្រាក់ពីការទូទាត់តាមRHB Pay Anyone™ ដែលទទួលបានការផ្ញើសារខ្លី (ផ្ញើសារអេឡិចត្រូនិក) ពីធនាគារតាមរយៈ អ៊ីម៉ែល ឬ ទំព័រ Facebook ឯកជនដែលបានជូនដំណឹងពីការទូទាត់តាមសេវា RHB Pay Anyone™ ដែលអ្នកទទួលអាចធ្វើការទទួលប្រាក់បានតាមរយៈ RHB Pay Anyone™ ជម្រើសបណ្តាញ ឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow ។

1.21 ការទទួលប្រាក់ពី ការទូទាត់តាមសេវា RHB Pay Anyone™

១. អ្នកនឹងទទួលបានការជូនដំណឹងពីធនាគារថា ការទូទាត់តាមRHB Pay Anyone™ អាចធ្វើការទទួលប្រាក់បានតាមរយៈ សារអេឡិចត្រូនិក / អ៊ីម៉ែល / ទំព័រ Facebook ឯកជន បាន។ ធនាគារនឹងព្យាយាមផ្ញើសារអេឡិចត្រូនិក / អ៊ីម៉ែល / ទំព័រ Facebook ឯកជនដើម្បីជូនដំណឹងដល់អ្នកអោយឆាប់រហ័សបន្ទាប់ពីអ្នកផ្ញើបានធ្វើប្រតិបត្តិការ RHB Pay Anyone ™ ចប់សព្វគ្រប់។ ប៉ុន្តែធនាគារមិនទទួលខុសត្រូវចំពោះការពន្យាពេលក្នុងការផ្ញើសារអេឡិចត្រូនិក / អ៊ីម៉ែល / ទំព័រ Facebook ឯកជនទៅឱ្យអ្នកឡើយ។

២. ដើម្បីអាចអោយអ្នកទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ អ្នកផ្ញើត្រូវធ្វើការណែនាំអ្នកអំពីការរបៀបនៃការទទួលប្រាក់ នឹងផ្តល់លេខកូដសម្ងាត់តាមរយៈការហៅទៅកាន់អ្នកដោយផ្ទាល់។

៣. ការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone ™ តាមរយៈRHB Pay Anyone™ ជម្រើសបណ្តាញ ឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow អ្នកត្រូវតែបំពេញ:

ក. លេខកូដសម្ងាត់

ខ. លេខទូរស័ព្ទចល័ត / អ៊ីម៉ែល / ឈ្មោះគណនី Facebook របស់អ្នក;

គ. ពត៌មានលំអិតអំពីលេខគណនីរបស់អ្នកដែលអ្នកចង់អោយការទូទាត់សេវា RHB Pay Anyone™ ធ្វើការដាក់ប្រាក់ចូល ។

៤. ប្រសិនបើអ្នកមិនបំពេញព័ត៌មានតម្រូវដែលបានបញ្ជាក់ក្នុងចំណុច ៣ (គ)នោះទេនោះការទទួលប្រាក់របស់អ្នកពីការទូទាត់តាម RHB Pay Anyone™ នឹងមិនទទួលជោគជ័យ។

៥. ព័ត៌មានលំអិតទាំងអស់ដែលអ្នកបានបំពេញគឺត្រូវតែត្រឹមត្រូវ។ សម្រាប់ការដំណើរការ RHB Pay Anyone™ តាមរយៈ RHB Pay Anyone™ ជម្រើសបណ្តាញ ឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHB Now ធនាគារមិនមានកាតព្វកិច្ចក្នុងការពិនិត្យលើលេខគណនីដែលអ្នកបានបំពេញគឺត្រឹមត្រូវ និង/ឬផ្ទៀងផ្ទាត់ឈ្មោះគណនី ឬព័ត៌មានលម្អិតដែលបានបំពេញឡើយ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ ធនាគារនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ឬការខូចខាតណាមួយដែលកើតឡើងពីកំហុសណាមួយដែលបង្កឡើងដោយការណែនាំរបស់អ្នកដែលមិនត្រឹមត្រូវ ដែលជាលទ្ធផលធ្វើអោយអ្នកមិនអាចទទួលបានប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ ។

៦. អ្នកត្រូវធ្វើការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ ក្នុងរយៈពេលបី (៣) ថ្ងៃគិតចាប់ពីថ្ងៃប្រតិបត្តិការដូចដែលបានបង្ហាញនៅក្នុងលក្ខខណ្ឌ និង ខចែង("រយៈពេលមានសុពលភាព") ។ ប្រសិនបើអ្នកបរាជ័យក្នុងការទទួលប្រាក់ពី ការទូទាត់តាមសេវា RHB Pay Anyone™ ក្នុងរយៈពេលមានសុពលភាព សំណើការទូទាត់តាមសេវា RHB Pay Anyone™ នឹងត្រូវបានលុបចោលដោយស្វ័យប្រវត្តិ ហើយប្រាក់ដែលដាក់ទូទាត់នឹងនៅតែជាកម្មសិទ្ធិរបស់អ្នកផ្ញើ។ អ្នកមិនអាចធ្វើការទទួលប្រាក់ដែលបានទូទាត់តាមសេវា RHB Pay Anyone™ បន្ទាប់ពីរយៈពេលមានសុពលភាពនោះទេ។

៧. មុនពេលដាក់ដំណើរការប្រតិបត្តិការទទួលប្រាក់ពីការទូទាត់ តាមសេវា RHB Pay Anyone™ ដោយធនាគារ ទឹកប្រាក់ដែលត្រូវទូទាត់នឹងនៅតែជាទ្រព្យសម្បត្តិរបស់អ្នកផ្ញើ ហើយធនាគារមានសិទ្ធិលុបចោលសិទ្ធិរបស់អ្នកក្នុងការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ នោះ មុនពេលដែលអ្នកធ្វើប្រតិបត្តិការទទួល។

៨. ប្រសិនបើការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ តាមរយៈ RHB Pay Anyone ™ តាមរយៈ RHB Pay Anyone™ ជម្រើសបណ្តាញ ឬ ការទទួលប្រាក់តាមកម្មវិធីធនាគារចល័ត RHBNow ទទួលបានជោគជ័យ ការទូទាត់តាមRHB Pay Anyone ™ នឹងបញ្ជូនប្រាក់ចូលទៅក្នុងគណនីធនាគារដែលអ្នកបានកំណត់តាមរយៈសេវាទូទាត់រហ័ស (FAST)។

៩ អ្នកមិនត្រូវ:

ក. បង្ហាញលេខកូដសម្ងាត់ទៅបុគ្គលផ្សេងទៀត។ ឬ

ខ. កត់ត្រាលេខកូដសម្ងាត់ លើកន្លែងដែលងាយបាត់បង់ លួច ឬបន្លំ។

១០. ធនាគារមិនទទួលខុសត្រូវចំពោះ:

ក. ការបរាជ័យ ឬការពន្យាពេលណាមួយដោយអ្នកផ្ញើក្នុងការផ្តល់ព័ត៌មាន ប្រតិបត្តិការត្រឹមត្រូវដល់អ្នក ដើម្បីធ្វើការទទួលប្រាក់ពីការទូទាត់តាមសេវា RHB Pay Anyone™ (រួមបញ្ចូលទាំងកូដសម្ងាត់);

ខ. ប្រសិនបើបុគ្គលផ្សេងក្រៅពីអ្នកដឹងលេខកូដសម្ងាត់;

គ. ប្រសិនបើលេខកូដសម្ងាត់ឬព័ត៌មានលំអិតរបសព្វគណនីដែលបំពេញដោយអ្នកមិនត្រឹមត្រូវ;

ឃ. ប្រសិនបើធនាគារ RHB លុបចោលការទូទាត់តាមសេវា RHB Pay Anyone™ របស់អ្នកមុនពេលដែលអ្នកធ្វើការទទួលយក;និង

ង. ប្រសិនបើធនាគារ RHB ពន្យារ បញ្ឈប់ ឬ បដិសេធមិនដំណើរការ ការទូទាត់តាមសេវា RHB Pay Anyone™ ដោយហេតុផលណាមួយ។

១១. អ្នកត្រូវទាក់ទងទៅអ្នកផ្ញើប្រសិនអ្នកមិនអាចធ្វើការទទួលប្រាក់បានពីការទូទាត់តាមសេវា RHB Pay Anyone™ ឬអ្នកមានបំណងចង់តវ៉ានឹងចំនួនទឹកប្រាក់ដែលទទួលពីការទូទាត់តាមសេវា RHB Pay Anyone™

1.22 ការយល់ព្រមលើការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន

១. ធនាគារនឹងប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក (ឧទាហរណ៍លេខទូរស័ព្ទ អ៊ីម៉ែល ឈ្មោះគណនីFACEBOOK និង / ឬព័ត៌មានគណនីធនាគារ) ដើម្បីអោយអ្នកអាចដំណើរការការទទួលប្រាក់របស់អ្នកពីការទូទាត់តាមសេវា RHB Pay Anyone™។ ប្រសិនបើគ្មានព័ត៌មាននេះ ធនាគារ មិនអាចដំណើរការការទទួលប្រាក់របស់អ្នកតាមសេវា RHB Pay Anyone™ បាននោះទេ។

២. អ្នកព្រមព្រៀងនិងយល់ព្រមចំពោះការគ្រប់គ្រង ការប្រមូលនិងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនទាំងអស់ដែលបានផ្តល់អោយធនាគារតាមរយៈទំព័រទំនាក់ទំនងសាធារណៈក៏ដូចជាទិន្នន័យផ្ទាល់ខ្លួនដែលទទួលបានពីការប្រើប្រាស់សេវាទូទាត់តាម RHB Pay Anyone™ ដោយអនុលោមតាមគោលនយោបាយសិទ្ធិឯកជនរបស់ធនាគារដែលអាចត្រូវបានធ្វើវិសោធនកម្មជានិច្ចកាល។

1.23 ការទូទាត់សំណង

អ្នកយល់ព្រមនិងទទួលស្គាល់ថាធនាគារមិនធានាឬអះអាងណាមួយ ទៅលើកម្មវិធីធនាគារអ៊ីនធឺណែត កម្មវិធីធនាគារចល័ត RHBNow និង / ឬ សេវា RHB Pay Anyone™ ដែលផ្តល់ដោយធនាគារឡើយ។ នេះ ធនាគារមិនធានានិងទទួលខុសត្រូវចំពោះការបាត់បង់ផ្សេងៗរបស់អ្នកឬបុគ្គលផ្សេងទៀត ដែលមានកើតឡើងដោយការមិនគោរពតាមសំណងទាក់ទងនឹងលក្ខខណ្ឌនេះឡើយ។